# វិទ្យាល័យ
# SOUTH OAKLEIGH COLLEGE

កម្មវិធីសិក្សាសម្រាប់សិស្សអន្តរជាតិ

## រដ្ឋវិកតូរៀ ប្រទេសអូស្ត្រាលី

នាយកដ្ឋានអប់រំ



Victoria
State Government
Australia



សិស្សរបស់យើងមានសមត្ថភាពក្នុងការពិចារណាលើទស្សនៈខុសៗគ្នា អភិវឌ្ឍន៍ចិត្តមេត្តា កសាងទំនាក់ទំនងវិជ្ជមាន និងធ្វើសេចក្ដីសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់។



# សារពីនាយកសាលា

**វិទ្យាល័យ South Oakleigh College ប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍន៍កុមារទាំងមូល។ សិស្សម្នាក់ៗសុទ្ធតែមានទេពកោសល្យ ហើយយើងផ្តល់ជូននូវឱកាសដ៏សម្បូរបែប ធ្វើដូច្នេះទើបសិស្សម្នាក់ៗអាចសម្រេចបាននូវសក្តានុពលរបស់ខ្លួន និងក្លាយទៅជាសិស្សដែលមានទំនុកចិត្ត ការគោរព និងមានប្រសិទ្ធភាព អាចចូលរួមចំណែកជាការស្ថាបនាក្នុងនាមជាពលរដ្ឋសកលនៃសតវត្សរ៍ទី 21។**
សិស្សរបស់យើងរៀនអំពីភាពតស៊ូ ដើម្បីពុះពារព្យាយាម និងចេះប្រើផនធានដែលខ្លួនមាននៅពេលជួបប្រទះនឹងបញ្ហាប្រឈម និងទទួលខុសត្រូវចំពោះការរៀនសូត្ររបស់ខ្លួនតាមរយៈការធ្វើខ្លួនឱ្យមានភាពច្នៃប្រឌិត។ យើងអបអរចំពោះភាពចម្រុះរបស់សិស្ស និងលើកទឹកចិត្តពួកគេឱ្យអភិវឌ្ឍន៍ទំនួលខុសត្រូវសង្គម ចិត្តមេត្តា និងការចេះស្រឡាញ់រាប់អានគ្នាទៅវិញទៅមក។

វិទ្យាល័យ South Oakleigh College ផ្តល់ជូននូវកម្មវិធីសិក្សាគ្រប់ជ្រុងជ្រោយ និងមានលក្ខណៈប្រកួតប្រជែងដែលគាំទ្រដោយកម្មវិធីសិក្សាបន្ថែមដែលមានភាពបត់បែន។ គុណតម្លៃរបស់យើងចំពោះក្តីរំពឹង ការគោរព ទំនួលខុសត្រូវ ការតស៊ូ និងការងារជាក្រុមកម្រិតខ្ពស់ គឺត្រូវបានបណ្តុះតាមរយៈគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតនៅសាលារៀន ពោលគឺនៅក្នុងអំឡុងពេលសិក្សារបស់សិស្ស នៅពេញការអនុវត្តការបង្រៀន និងនៅក្នុងការគ្រប់គ្រងសាលារៀន។

យើងមានក្តីសោមនស្សរីករាយ ដែលលោកអ្នកពិចារណាលើសហគមន៍ដ៏រីកចម្រើនលូតលាស់របស់យើង ជាវិថីសម្រាប់កូនៗរបស់លោកអ្នក។ សូមមេត្តាទំនាក់ទំនងជាមួយវិទ្យាល័យ ប្រសិនបើអ្នកមានសំណួរនានាពាក់ព័ន្ធនឹងសាលារៀន និងកម្មវិធីដែលសាលាផ្តល់ជូន។

**Helen Koziaris**
**នាយកសាលា**



## មូលហេតុត្រូវជ្រើសរើសយកវិទ្យាល័យ SOUTH OAKLEIGH COLLEGE?

**នៅវិទ្យាល័យ South Oakleigh College កម្មវិធីសិក្សាសម្រាប់សិស្សអន្តរជាតិដ៏ជោគជ័យរបស់យើង គឺទទួលបានការទទួលស្គាល់គុណភាព និងរៀប ទទួលក្រុមសិស្សមកពីមជ្ឈដ្ឋានចម្រុះ។ យើងផ្តល់នូវបរិយាកាសប្រកបដោយការគាំទ្រ និងការជំរុញសម្រាប់គ្រប់សិស្សទាំងអស់ និងកម្មវិធីសិក្សាគ្រប់ជ្រុ ជ្រោយដែលត្រូវបានរចនាឡើង ដើម្បីជួយដល់សិស្សឱ្យទទួលបានជោគជ័យនៅក្នុងការសិក្សាបន្ត ការងារ និងជីវិតនៅក្នុងពិភពលោកដែលមានការផ្លាស់ប្ដូ យ៉ាងលឿននេះ។**

យើងពិតជាមានមោទនភាពក្នុងការផ្ដល់ជូននូវ៖

- ការសិក្សាភាសាអង់គ្លេសកម្រិតខ្ពស់ជា កម្មវិធីភាសាបន្ថែម (EAL)
- ជំនួយការកម្មវិធីសិក្សាសម្រាប់សិស្សអន្តរជាតិ ដែលផ្ដល់ឱ្យសិស្សម្នាក់ៗនូវការគាំទ្រ និងការបង្ហាត់បង្រៀនបន្ថែម
- ក្លិបកិច្ចការបន្ទាប់ពីម៉ោងសិក្សា
- ផែនការអប់រំស្របតាមសិស្សម្នាក់ៗ ដែលត្រូវបានរចនាឡើងសម្រាប់បំពេញតម្រូវការ និងមជ្ឈដ្ឋានខុសៗគ្នារបស់សិស្សម្នាក់ៗ
- សកម្មភាពកម្មវិធីសិក្សាបន្ថែមដ៏សម្បូរបែប រួមទាំងដំណើរកម្សាន្តដែលមានតម្លៃអប់រំ និងវប្បធម៌ ការចុះទស្សនកិច្ចតាមសាកល
  វិទ្យាល័យ និងឱកាសក្នុងការចូលរួមនៅក្នុងក្លិបពង្រឹងសមត្ថភាព ក្រុមកីឡា និងកម្មវិធីប្រកួតប្រជែងនានាទាំងក្នុង និងក្រៅម៉ោងសិក្សា
- ការគាំទ្រជាបន្តបន្ទាប់ រួមទាំងវគ្គពិគ្រោះយោបល់ម្នាក់ៗ និងសិក្ខាសាលាស្ដីពីសុខភាពផ្លូវចិត្តដែលផ្ដល់ជូនដោយដៃគូខាងក្រៅសាលា។

### កម្មវិធីសិក្សាគុណភាពខ្ពស់

កម្មវិធីពន្លឿនការសិក្សារបស់សាលា គឺត្រូវបានបង្កើតឡើង ដើម្បីផ្ដល់ជាការប្រកួតប្រជែងដល់សិសិស្សពូកែឱ្យប្រឹងប្រែងអស់ពីសមត្ថភាព។ កម្មវិធីនេះ មានគោលបំណងអភិវឌ្ឍន៍ជំនាញត្រិះរិះពិចារណាលំដាប់ខ្ពស់ ធ្វើដូច្នេះទើបសិស្សអាចទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅអំពីប្រធានបទនានាដែលសិក្សាជាភាសាអង់គ្លេស គណិតវិទ្យា និងវិទ្យាសាស្ត្រ។

អ្នកប្រឹក្សាយោបល់អាជីពការងារ និងវិថីសិក្សារបស់យើង ទទួលខុសត្រូវចំពោះការពិគ្រោះយោបល់អាជីពការងារ និងវគ្គសិក្សា រក្សានូវប្រភព ឯកសារពាក់ព័ន្ធដ៏សម្បូរបែបសម្រាប់ឱ្យសិស្សប្រើប្រាស់ និងជួយចុះឈ្មោះសិស្សដែលមានវិញ្ញាបនបត្រអប់រំរដ្ឋវិកតូរៀន (VCE) ចូលរៀនវគ្គសិក្សាពាក់ព័ន្ធផងដែរ។ កិច្ចការនេះ មានគោលបំណងផ្ដល់ជូនសិស្សនូវព័ត៌មានពាក់ព័ន្ធទាំងអស់ ដែលជំរុញឱ្យពួកគេធ្វើការសម្រេចចិត្តជ្រើសរើសដែលមានព័ត៌មានគ្រប់គ្រាន់សម្រាប់ជីវិតរបស់ពួកគេ។



### ទស្សនាទានរបស់ប្រធានថ្នាក់សកល

វិទ្យាល័យ South Oakleigh College មានគ្រូបង្រៀនមកពីមជ្ឈដ្ឋានវប្បធម៌ចម្រុះ ដែលអាចជួយណែនាំអ្នកជាភាសាដែលអ្នកត្រូវការអំពីមុខវិជ្ជាខុសៗគ្នាជាច្រើន រួមទាំង វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) និងសិល្បៈ។ សាលាផ្ដល់ជូននូវកម្មវិធីបង្ហាត់បង្រៀនបន្ថែម ដែលអាចជួយអភិវឌ្ឍន៍ការយល់ដឹងរបស់សិស្សអំពីអក្ខរកម្មលេខ និងមនុស្សសាស្ត្រ។

វិទ្យាល័យ South Oakleigh College ផ្ដល់ជូននូវកម្មវិធីភាសាអន្តរជាតិ ដែលរួមមានវគ្គសិក្សាភាសាក្រិក និងជប៉ុន។ ដើម្បីចុះឈ្មោះក្នុងកម្មវិធីនេះ សិស្សអាចជ្រើសរើសវគ្គសិក្សាភាសាដែលពួកគេចង់ចូលរៀន ក្នុងអំឡុងការជ្រើសរើសមុខវិជ្ជានៅពេលចាប់ផ្ដើមឆ្នាំសិក្សា។ វគ្គសិក្សាភាសាទាំងនេះ បើកដំណើរការនៅក្នុងសាលាផ្ទាល់ ហើយយើងផ្ដល់ជូននូវវគ្គសិក្សាភាសាទាំងនេះក្នុងកម្រិតខ្ពស់ កម្រិតមធ្យម និងកម្រិតមូលដ្ឋាន ដូច្នេះកុំចាំបាច់បារម្ភថាអ្នកមិនទាន់មានទំនុកចិត្តអី!

ការសិក្សាភាសាទាំងនេះ អាចផ្ដល់នូវការយល់ដឹងកាន់តែស៊ីជម្រៅ និងការស្ញប់ស្ញែងចំពីវប្បធម៌ដែលភ្ជាប់មកជាមួយនឹងភាសាទាំងនោះ។ តាមរយៈការរៀនភាសាទាំងនេះ សិស្សអាចទទួលបាននូវទស្សនៈអំពីទំនៀមទម្លាប់ គុណតម្លៃ និងជំនឿរបស់សហគមន៍ជាក់លាក់។ ឧទាហរណ៍ តាមរយៈការរៀនភាសាក្រិក សិស្សអាចរៀនអំពីអរិយធម៌ក្រិកបុរាណ ទេវកថា និងអក្សរសាស្ត្រ ក៏ដូចជាវប្បធម៌ក្រិកសម័យទំនើបផងដែរ។ ស្រដៀងគ្នានេះដែរ ការរៀនភាសាជប៉ុនអាចឱ្យសិស្សយល់ដឹងនូវបេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែបរបស់ប្រទេសជប៉ុន រួមទាំងប្រពៃណី សិល្បៈ និងបច្ចេកវិទ្យារបស់ជប៉ុនផងដែរ។

បន្ថែមពីលើការពង្រីកចំណេះដឹងផ្នែកវប្បធម៌ ការរៀនភាសាថ្មីក៏ផ្ដល់នូវផលប្រយោជន៍ដែលអាចយកទៅអនុវត្តជាក់ស្ដែងផងដែរ។ លើសពីនេះ ការរៀនភាសានេះ អាចរៀបចំសិស្សសម្រាប់ការធ្វើដំណើរអន្តរជាតិ និងឱកាសការងារនាពេលអនាគត។

យើងទន្ទឹងរង់ចាំទទួលស្វាគមន៍សិស្សអន្តរជាតិទាំងអស់ដែលចូលមកកាន់វិទ្យាល័យរបស់យើង និងផ្ដល់ជំនួយនៅក្នុងការអភិវឌ្ឍន៍ចំណេះដឹងអំពីវប្បធម៌ និងភាពចម្រុះ នៅក្នុងសហគមន៍ប្រកបដោយ បរិយាប័ន្នដ៏ទូលំទូលាយរបស់យើង។

យើងសង្ឃឹមថានឹងជួបអ្នកនៅព្រឹត្តិការណ៍ណាមួយក្នុងចំណោមព្រឹត្តិការណ៍ជាច្រើនរបស់យើង រួមទាំងពិធីបុណ្យចូលឆ្នាំចិន (រួមបញ្ចូលទាំងទំនៀមទម្លាប់ជនជាតិចិន និងវៀតណាម) ពិធីបុណ្យសែនព្រះខែនាពាក់កណ្ដាល់រដូវស្លឹកឈើជ្រុះ បុណ្យ Diwali និងកម្មវិធីជាច្រើនទៀត។

**Sally Wu, Thanh Viet និង Phuc (Mollie) Pham**

**ប្រធានថ្នាក់សកល ឆ្នាំ202**





## សកម្មភាពផ្សេងៗក្រៅកម្មវិធីសិក្សាដ៏សម្បូរបែប

យើងផ្តល់ជូនសិស្សនូវឱកាសដ៏សម្បូរបែបក្នុងការរុករកការរៀនសូត្រ ការពង្រឹងមិត្តភាពឱ្យកាន់តែជិតស្និទ្ធ និងការអភិវឌ្ឍន៍សិស្សមានទេពកោសល្យថ្មីៗតាមរយៈកម្មវិធីក្រៅកម្មវិធីសិក្សារបស់យើង។ កម្មវិធីទាំងនេះរួមមាន៖

- ការប្រកួតប្រជែងការសិក្សា
- ល្បែងអុក
- វង់ភ្លេង
- ការសរសេរកូត IT
- ការបង្រៀនអំពីសាកលវិទ្យាល័យ Monash University
- ការជជែកតស៊ូមតិ
- ការផលិតភាពយន្ត និងវីដេអូសាលា
- ក្លិបអាហារពេលព្រឹក
- ក្លិបកម្មវិធីទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយ
- ក្លិប lego
- កម្មវិធីចែករំលែកបទពិសោធន៍ការងារ
- ក្លិបកាយសិក្សា (ការហាត់ប្រាណ)
- ក្លិប STEM
- ក្លិបសិល្ប: និងរចនា

ចាប់ពីឆ្នាំទី 7 ដល់ឆ្នាំទី 11 សិស្សចូលរួមកម្មវិធីបោះជំរុំសាលាជារៀងរាល់ឆ្នាំ ដែលនេះជាមធ្យោបាយមួយដ៏ល្អបំផុតក្នុងការកសាងទំនាក់ទំនងថ្មីៗតាមរយៈសកម្មភាពដែលមានលក្ខណៈប្រកួតប្រជែង ដែលបង្រៀនសិស្សម្នាក់ៗអំពីតម្លៃនៃការតស៊ូ និងទំនុកចិត្តរវាងគ្នានឹងគ្នា។ សិស្សចុះទស្សនកិច្ចទិសដៅទេសចរណ៍ពេញនិយមជាច្រើននៅជុំវិញរដ្ឋវីកតូរៀ ដូចជាកោះហ្វីលីព ហ្គីពស៍ឡេន និងហ្គែលឡុង។ ដោយមាននូវឱកាសបន្ថែមក្នុងការចូលរួមនៅក្នុងកម្មវិធីបញ្ញាវប្បធម៌ និងភាសានៅក្រៅប្រទេស ដូចជាការដកស្រង់បទពិសោធន៍ STEM នៅNASA គម្រោងសហគមន៍នៅហ្វីជី ដំណើរបញ្ញាវប្បធម៌ទៅប្រទេសក្រិក ជប៉ុន និងដែនដីភាគខាងជើងជាដើម។

នៅវិទ្យាល័យ South Oakleigh College យើងពិតជាមានមោទនភាពណាស់ចំពោះមជ្ឈមណ្ឌលប្រព័ន្ធផ្សព្វផ្សាយរបស់យើង។ ដោយមាននូវបរិក្ខារសម្រាប់វិជ្ជាជីវៈទំនើបចុងក្រោយបំផុត រួមទាំងកាមេរ៉ា ឧបករណ៍ផ្លាស់ប្តូរកាមេរ៉ា (vision-switching) ការផ្សព្វផ្សាយពីចំងាយ (tele- prompting) និងបរិក្ខារសំឡេង ដែលប្រើប្រាស់ដោយស្ថានីយទូរទស្សន៍ជាតិ។ យោងតាមលោក Anchor Peter Hitchener អ្នករាយការណ៍នៃព័ត៌មាននៅ Channel Nine News បានលើកឡើងថា “មជ្ឈមណ្ឌលនេះ គឺជាមជ្ឈមណ្ឌលទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយដ៏ល្អបំផុតមួយដែលខ្ញុំមិនធ្លាប់បានឃើញពីមុនមកទេនៅថ្នាក់វិទ្យាល័យ។”



## យកចិត្តទុកដាក់យ៉ាងម៉ឺងម៉ាត់ចំពោះសុខមាលភាពសិស្ស

កម្មវិធីសិក្សាសម្រាប់សិស្សអន្តរជាតិរបស់យើង គឺទទួលបានការគាំទ្រពីក្រុមការងារអន្តរជាតិ ដែលប្តេជ្ញាចិត្តគាំទ្រដល់សិស្សគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតនៅសាលារៀនរបស់ពួកគេ។

ក្រុមការងារសិស្សអន្តរជាតិរបស់យើង មានសមាសភាពដូចជា នាយកសាលា និងនាយកសាលារង អ្នកសម្របសម្រួលសិស្សអន្តរជាតិ និងជំនួយការសិស្សអន្តរជាតិ គ្រូបង្រៀនជំនួយពហុវប្បធម៌ និងគ្រូបង្រៀនភាសាអង់គ្លេស និងភាសាបន្ថែម (EAL) របស់យើង។

ក៏ដូចជាគ្រូតាមមុខវិជ្ជាផងដែរ សិស្សអន្តរជាតិ ក៏ទទួលបានការគាំទ្រដោយប្រធានសាលា គ្រូបណ្តុះបណ្តាល អ្នកសម្របសម្រួលអាជីពការងារ/វិថីសិក្សា ក្រុមការងារសុខុមាលភាព និងអ្នកដឹកនាំអនុសាលា។

ដើម្បីជាជំនួយដល់សិស្សអន្តរជាតិនៅក្នុងការសម្របខ្លួនទៅនឹងការសិក្សានៅប្រទេសអូស្ត្រាលី យើងមានបណ្តាញអ្នកជំនាញគាំទ្រដែលមានបទពិសោធន៍ជាច្រើនឆ្នាំនៅក្នុងការដោះស្រាយក្តីបារម្ភរបស់សិស្សមកពីវប្បធម៌ចម្រុះគ្នាជាច្រើន។ យើងមានមោទនភាពចំពោះគោលនយោបាយបើកចំហរបស់យើងទាក់ទងនឹងការផ្តល់ការគាំទ្រដល់សិស្ស ដោយយើងលើកទឹកចិត្តឱ្យសិស្សចេះស្វែងរកជំនួយ និងការណែនាំតម្រង់ទិសនៅពេលដែលពួកគេត្រូវការ។

## ផ្ទះស្នាក់សម្រាប់សិស្សអន្តរជាតិ

នៅរដ្ឋវិកតូរៀ គ្រួសារផ្ទះស្នាក់សម្រាប់សាលារបស់រដ្ឋាភិបាលទាំងអស់ សុទ្ធតែផ្តល់នូវ៖

- កន្លែងស្នាក់នៅដែលមានសុវត្ថិភាព សន្តិសុខ និងពោរពេញដោយការទទួលស្វាគមន៍
- គ្រួសារអនុលោមតាមស្តង់ដារការពារសុវត្ថិភាពកុមារ
- បន្ទប់ទោលដាច់ដោយឡែកសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នក
- អាហារបីពេលក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ រួមទាំងអាហារសម្រន់
- សម្ភារៈផ្តល់ជូន – គ្រែគេងមួយ ទូសម្លៀកបំពាក់មួយ និងខ្នើយភួយ
- សេវាប្រើប្រាស់ – ហ្គាស អគ្គិសនី ប្រព័ន្ធកម្ដៅ និងទឹក អ៊ីនធឺណិត
- សេវាសម្អាតនៅបរិវេណប្រើប្រាស់រួម
- ការប្រើប្រាស់បរិវេណទទួលភ្ញៀវនៅក្នុងផ្ទះ
- សម្ភារៈសិក្សា – តុ អំពូលសិក្សា ទូសៀវភៅ
- ការចូលរួមនៅការប្រជុំឪពុកម្តាយ/គ្រូបង្រៀនជំនួសឱ្យឪពុកម្តាយរបស់អ្នក។

សិស្សអន្តរជាតិមួយចំនួននៃវិទ្យាល័យ South Oakleigh របស់យើង រស់នៅជាមួយឪពុកម្តាយ ឬសាច់ញាតិដែលបានអនុញ្ញាតរបស់ពួកគេ។ សាច់ញាតិរបស់សិស្សម្នាក់ឈ្មោះ Jessica មានពាក្យចង់និយាយអំពីកម្មវិធីនេះ៖

“ការសិក្សានៅក្រៅប្រទេសអាចមានការលំបាក និងជួបបញ្ហាប្រឈមសម្រាប់សិស្សអន្តរជាតិ ប៉ុន្តែក្មួយស្រីរបស់ខ្ញុំ Tris បាន និងកំពុងតែសប្បាយរីករាយនឹងដំណើរសិក្សារបស់អ្នកនៅក្នុងប្រទេសអូស្ត្រាលី។ ខាងសាលារក្សាទំនាក់ទំនងជាមួយយើង ដោយផ្ញើអ៊ីមែលអំពីកំណត់ត្រាវត្តមានមកឱ្យយើងរបាយការណ៍ប្រចាំឆមាស និងពិនិត្យមើលសុខុមាលភាពរបស់សិស្ស។ កម្មវិធីនេះជួយយើងឱ្យដឹងថា កូនៗរបស់យើងគឺទទួលបានការថែទាំល្អ ហើយខាងសាលាតែងតែគាំទ្រដល់សិស្សអន្តរជាតិទាំងការសិក្សា ក៏ដូចជាសុខភាព និងសុខុមាលភាពរបស់សិស្សផងដែរ។”

## ទីតាំងងាយស្រួលរក

វិទ្យាល័យ South Oakleigh College មានទីតាំងស្ថិតនៅជាយក្រុងភាគអាគ្នេយ៍ ទីក្រុងមែលប៊ើន នៅក្នុងតំបន់ដែលមានខ្សែរថភ្លើង និងរថយន្តក្រុងខ្វាត់ខ្វែង។ វិទ្យាល័យនេះ មានទីធ្លាសាលាដ៏គួរឱ្យទាក់ទង និងស្ថិតនៅក្បែរឧទ្យានជាតិ និងព្រៃអភិរក្ស។ វិទ្យាល័យ South Oakleigh College ក៏ស្ថិតនៅក្បែរ៖

- សាកលវិទ្យាល័យ Monash University សាខា Clayton
- មជ្ឈមណ្ឌលកីឡា និងអាងហែលទឹក បណ្ណាល័យសហគមន៍ និងភោជនីយដ្ឋានជាច្រើន ដែលមានមុខម្ហូបជាច្រើនប្រភេទចម្រុះគ្នា
- មជ្ឈមណ្ឌលលក់ទំនិញ Chadstone - មជ្ឈមណ្ឌលលក់ទំនិញធំបំផុតនៅភាគខាងត្បូងប្រទេស។




## រឿងរ៉ាវជោគជ័យកាលពីពេលថ្មីៗ

*"ខ្ញុំបាន និងកំពុងសិក្សានៅវិទ្យាល័យ South Oakleigh College តាំងពីថ្នាក់ទី 8 ហើយពេលវេលារបស់ខ្ញុំគឺពោរពេញទៅដោយទាំងអនុស្សាវរីយ៍ល្អៗ និងលំបាកៗជាច្រើន។ ខ្ញុំដឹងថាវាមានការលំបាកខ្លាំងក្នុងការនៅកន្លែងថ្មីដែលអ្នកមិនធ្លាប់ស្គាល់ ប៉ុន្តែនៅពេលដែលអ្នកចាប់ផ្តើមបើកចំហចិត្ត*

*ទទួលយកមនុស្សថ្មីៗ អ្នកនឹងស្វែងយល់ឃើញថា គង់តែមាននរណាម្នាក់នៅជុំវិញខ្លួនអ្នកនឹងគាំទ្រអ្នកគ្រប់ពេលជានិច្ច។ តាមបទពិសោធន៍របស់ខ្ញុំផ្ទាល់ក្នុងនាមជាប្រធានសិស្សអន្តរជាតិមួយរូបទាំងនៅថ្នាក់ទី 9 និងថ្នាក់ទី 12 ខ្ញុំបានអភិវឌ្ឍន៍ជំនាញភាពជាអ្នកដឹកនាំ និងជំនាញសង្គម ដូច្នេះសូមកុំភ័យខ្លាចក្នុងការចាប់យកឱកាសទាំងនេះអី ដោយសារតែអ្នកមិនដឹងអ្នកនឹងទទួលបានផលប្រយោជន៍ច្រើនប៉ុណ្ណោះទេពីឱកាសទាំងនោះ។ ដោយ សារតែសិស្សអន្តរជាតិទាំងអស់គឺប្រៀបបានដូចជាគ្រួសារ ជំមួយ ពួកគេនឹងមើលថែរក្សាអ្នក។ ហើយភាសាអង់គ្លេសរបស់អ្នកនឹងកាន់តែរីកចម្រើនៗ"*

**- Maggie មកពីប្រទេសចិន ប្រធានសិស្សអន្តរជាតិនៅឆ្នាំ2021។ សិក្សាជំនាញចិត្តវិទ្យានៅសាកលវិទ្យាល័យ Monash University បន្ទាប់ពីបញ្ចប់ការសិក្សានៅវិទ្យាល័យ South Oakleigh College**

> **កម្មវិធីនេះជួយយើងឱ្យដឹងថា កូនៗរបស់យើងគឺទទួលបានការថែទាំល្អ ហើយខាងសាលាតែងតែគាំទ្រដល់សិស្សអន្តរជាតិទាំងការសិក្សា ក៏ដូចជាសុខភាព និងសុខុមាលភាពរបស់សិស្សផងដែរ។"**



SOUTH OAKLEIGH COLLEGE

## ទំនាក់ទំនងមកសាលា

**វិទ្យាល័យ South Oakleigh College**

ផ្លូវ Bakers Road, Oakleigh South 3167 រដ្ឋវិកតូរៀ

នាយកសាលា៖ Helen Koziaris
នាយកសាលារង៖ Anthony Katsianos

ទូរសព្ទ៖ +61 3 9579 2322
អ៊ីមែល៖ south.oakleigh.sc@education.vic.gov.au

VICTORIA State Government Australia

**សាលារបស់រដ្ឋាភិបាលរដ្ឋវិកតូរៀ**
**កម្មវិធីសិក្សាសម្រាប់សិស្សអន្តរជាតិ**
ផ្លូវ 80 Collins Street ទីក្រុងមែលប៊ើន រដ្ឋវិកតូរៀ 3000
ប្រទេសអូស្ត្រាលី
ទូរសព្ទ៖ +61 3 7022 1000
អ៊ីមែល៖ international@education.vic.gov.au
វែបសាយត៍៖ www.study.vic.gov.au
ចុះផ្សាយដោយផ្នែកអប់រំអន្តរជាតិ នាយកដ្ឋានអប់រំ
ទីក្រុងមែលប៊ើន ខែកុម្ភៈ ឆ្នាំ2023
© រដ្ឋវិកតូរៀ (នាយកដ្ឋានអប់រំ) ឆ្នាំ2023
ឈ្មោះ និងលេខកូដអ្នកផ្តល់សេវា CRICOS៖ នាយកដ្ឋានអប់រំ
00861K